# ព្រះរាជក្រម

នស/រកម/០៤២៦/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញក្នុងសេចក្តីសម្រេចលេខ០៣១/០០១/២០២៦ កបធ.ច ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត
# ជ្រើសតាំងសមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ .-**

មាត្រា៨ថ្មី មាត្រា៩ មាត្រា១០ មាត្រា១៤ មាត្រា១៧ មាត្រា១៨ មាត្រា២៣ និងមាត្រា២៨ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ និងបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់វិសោធនកម្មចុងក្រោយ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ (តទៅហៅថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា) ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា៨ .- ថ្មី(មួយ)**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយយករាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោត។ ការបែងចែកអាសនៈត្រូវធ្វើតាមមណ្ឌលបោះឆ្នោត និងត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដូចមានកំណត់ក្នុងមាត្រា១៣៥ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

**មាត្រា៩ .- ថ្មី**

អាសនៈនៅក្នុងព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវកំណត់ត្រឹមចំនួន **៥៨ (ហាសិបប្រាំបី)** ដោយបែងចែកតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ដូចខាងក្រោម៖

- មណ្ឌលខេត្តបន្ទាយមានជ័យ ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តបាត់ដំបង ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តកំពង់ចាម ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តត្បូងឃ្មុំ ចំនួន ៣ (បី) អាសនៈ
- មណ្ឌលខេត្តកំពង់ឆ្នាំង ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តកំពង់ស្ពឺ ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តកំពង់ធំ ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តកំពត ចំនួន ៣ (បី) អាសនៈ
- មណ្ឌលខេត្តកណ្តាល ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តកោះកុង ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តក្រចេះ ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តមណ្ឌលគិរី ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលរាជធានីភ្នំពេញ ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តព្រះវិហារ ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តព្រៃវែង ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តពោធិ៍សាត់ ចំនួន ១ (មួយ) អាសនៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- មណ្ឌលខេត្តរតនគិរី ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តសៀមរាប ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តព្រះសីហនុ ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តស្ទឹងត្រែង ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តស្វាយរៀង ចំនួន ៣ (បី) អាសនៈ
- មណ្ឌលខេត្តតាកែវ ចំនួន ៤ (បួន) អាសនៈ
- មណ្ឌលខេត្តកែប ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តប៉ៃលិន ចំនួន ១ (មួយ) អាសនៈ
- មណ្ឌលខេត្តឧត្តរមានជ័យ ចំនួន ១ (មួយ) អាសនៈ។

**មាត្រា១០ .. ថ្មី**

អ្នកបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង។

អង្គបោះឆ្នោត នៃមណ្ឌលនីមួយៗ គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ទាំងអស់នៅក្នុងមណ្ឌលបោះឆ្នោតនោះ។

**មាត្រា១៤ .. ថ្មី**

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃមណ្ឌលបោះឆ្នោតនីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិ រៀបតាមលំដាប់លេខរៀង ដូចការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ។

**មាត្រា១៧ .. ថ្មី**

ការឃោសនាបោះឆ្នោត ត្រូវធ្វើនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ។

យុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេល ១៤(ដប់បួន)ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤(ម្ភៃបួន)ម៉ោង មុនថ្ងៃបោះឆ្នោត។

**មាត្រា១៨ .. ថ្មី**

មាត្រា៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២នៃមាត្រា៧២ មាត្រា៧៣ ៧៤ ៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ និងបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់វិសោធនកម្មចុងក្រោយ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ (តទៅហៅថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ) ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ដោយឡែក ចំពោះការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅក្នុងមណ្ឌលបោះឆ្នោតនីមួយៗ ត្រូវកំណត់យ៉ាងច្រើន ២(ពីរ)ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

**មាត្រា២៣ .- ថ្មី**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត របស់ខ្លួន ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា២៨ .- ថ្មី(មួយ)**

មាត្រា១៣៨ថ្មី និងមាត្រា១៣៨ស្ទួនថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការបាត់បង់អាសនៈនៃព្រឹទ្ធសភា។

**មាត្រាពីរ .-**

បទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវយកទៅអនុវត្តចាប់ពីការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៦ តទៅ។

ថ្ងៃ សុក្រ ៨កើត ខែពិសាខ ឆ្នាំ មមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ពរសៈ ០៤២៦.០៤៥

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**